00841470 **E223**

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

**ភាសាដើម:** **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 29-Aug-2012, 11:13
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**មតិគាំទ្រសំណើរបស់លោក អៀង សារី E221 និងស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឲ្យ បង្គាប់ដល់សហព្រះរាជអាជ្ញាធ្វើការកែតម្រូវបញ្ជីសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដែល សហព្រះរាជអាជ្ញាមានបំណងដាក់បញ្ចូលក្នុងការពិភាក្សាដេញដោល ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់**

---

| ដាក់ដោយ៖ | ដាក់ជូន៖ |
|---|---|
| **មេធាវីការពារក្តីលោក ខៀវ សំផន** | **អង្គជំនុំជម្រះសាលាដំបូង៖** |
| មេធាវី គង់ សំអុន | ចៅក្រម និល ណុន |
| មេធាវី Anta GUISSÉ | ចៅក្រម Silvia CARTWRIGHT |
| មេធាវី Arthur VERCKEN | ចៅក្រម យូរ ឧត្តរា |
| មេធាវី Jacques VERGÈS | ចៅក្រម Jean-Marc LAVERGNE |

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mathilde CHIFFERT

កញ្ញា អ៊ុច ស្រីផាត់

កញ្ញា Soumeya MEDJEBEUR

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ មេធាវីការពារក្តីលោក អៀង សារី បានដាក់សំណើមួយទៅអង្គជំនុំជម្រះសាលាដំបូង សុំឱ្យធ្វើការស្តាប់សក្ខីកម្មរបស់អ្នកបកប្រែភាសាផ្ទាល់មាត់ ដែលបានចូលរួមក្នុងការស្តាប់យកចម្លើយលើកទីពីររបស់សាក្សីឈ្មោះ ភី ភួន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលការស្តាប់យកចម្លើយនោះត្រូវបានចោទប្រកាន់ថាធ្វើឡើងដោយមិនប្រក្រតី ក្រោមរូបភាពទុច្ចរិត[1]។

២. តាមរយៈសំណើសុំនេះ លោក ខៀវ សំផន សូមធ្វើការគាំទ្រចំពោះសំណើរបស់លោក អៀង សារី ដែលស្នើសុំឱ្យមានការស្តាប់សក្ខីកម្មសាក្សីបុគ្គលខាងលើ ទាក់ទងទៅនឹងលក្ខខណ្ឌនៃការប្រព្រឹត្តទៅនៃការស្តាប់យកចម្លើយសាក្សី ភី ភួន និងទាក់ទងទៅនឹងវិធីសាស្ត្រដែលអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានអនុវត្តដើម្បីទទួលបានសក្ខីកម្មពីលោក ភី ភួន[2]។

៣. លោក ខៀវ សំផន សូមគាំទ្រទាំងស្រុងទៅលើទឡ្ហីករណ៍ ដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តីលោក អៀង សារី ហើយយល់ឃើញថា សំណើសុំនេះពិតជាធ្វើឡើងដោយមានអំណះអំណាងគ្រប់គ្រាន់ ហើយនិងមានលក្ខណៈចាំបាច់ ដោយផ្អែកទៅលើបទបញ្ញត្តិនានាដែលមាននៅក្នុងច្បាប់ជាតិ និងនៅក្នុងច្បាប់អន្តរជាតិ សម្រាប់ដឹកនាំសវនាការលើសំណុំរឿង ០០២/០១ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក.។

៤. លោក ខៀវ សំផន យល់ស្របតាមមតិរបស់លោក អៀង សារី ដែលយល់ឃើញថា ភាពដែលគួរឱ្យជឿជាក់បានថាភាពមិនប្រក្រតីកើតឡើងក្នុងកិច្ចដំណើរការស្តាប់យកចម្លើយពីសាក្សីឈ្មោះ ភី ភួន តម្រូវឱ្យមានការស៊ើបអង្កេតថ្មីមួយជាចាំបាច់ពីសំណាក់អង្គជំនុំជម្រះ។ ហេតុដូច្នេះ លោក ខៀវ សំផន សូមស្នើ

[1] *សំណើរបស់ អៀង សារី សុំស្តាប់ការបង្ហាញភស្តុតាងពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី ភី ភួន លើកទីពីររបស់ ក.ស.ច.ស ដែលកើតមាននូវភាពមិនប្រក្រតី ដែលអាចនឹងចាត់ទុកថាជាការលេងល្បិចវៀក* ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ ឯកសារ **E221**។

[2] *យោងដូចខាងលើ* លើកលែងតែមានការបកប្រែសំណើនេះជាភាសាបារាំង។

ដល់អង្គជំនុំជម្រះសាលាដំបូងមេត្តាអនុវត្តសិទ្ធិអំណាចរបស់ខ្លួន ដូចដែលបានផ្តល់ជូនដោយវិធាន ៩៣ នៃវិធានផ្ទៃក្នុង។

៥. ម្យ៉ាងវិញទៀត លោក ខៀវ សំផន យល់ឃើញថា រូបភាពនៃអំពើទុច្ចរិតពាក់ព័ន្ធនឹងការកាលៈទេសៈនៃការប្រព្រឹត្តិទៅនៃការស្តាប់យកចម្លើយសាក្សីឈ្មោះ ភី ភួន ត្រូវតែបង្កើនការប្រុងប្រយ័ត្នដល់អង្គជំនុំជម្រះសាលាដំបូង។ សំណើសុំនានារបស់សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលស្នើសុំឱ្យមានការទទួលស្គាល់សក្ខីកម្មជាលាយលក្ខណ៍អក្សររបស់សាក្សីថាជាឯកសារភស្តុតាងអាចប្រើប្រាស់បានក្នុងពេលសវនាការ ជំនួសឱ្យការកោះហៅសាក្សីនោះមកផ្តល់សក្ខីកម្មផ្ទាល់ គឺជារឿងមួយដែលអង្គជំនុំជម្រះត្រូវធ្វើការប្រុងប្រយ័ត្នបំផុត។

៦. ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន បានរាប់ឃើញឯកសារនៃការផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សររបស់សាក្សីចំនួន ២២៨ ដែលបានស្នើសុំដូចគ្នាឱ្យដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សាដេញដោលនូវសក្ខីកម្មទាំងឡាយដែលទាក់ទងទៅនឹងដំណាក់កាលទី ១ និង ទី ២ នៃការជម្លៀសប្រជាជន[3]។ កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានដាក់សំណើបន្ថែមមួយទៀត សុំឱ្យមានការដាក់បញ្ចូលសក្ខីកម្មជាលាយលក្ខណ៍អក្សរ និង ឯកសារប្រតិចារឹកនៃការស្តាប់យកចម្លើយសាក្សីទៅក្នុងការពិភាក្សាដេញដោល (“សំណើសុំបន្ថែម”)[4]។ សំណើសុំបន្ថែមនេះមានបំណងស្នើឱ្យទទួលស្គាល់សក្ខីកម្មជាលាយលក្ខណ៍អក្សរចំនួន ២១៨៨ ព្រមទាំងឯកសារផ្សេងទៀតពាក់ព័ន្ធទៅនឹងសាក្សីចំនួន ១២៩១ នាក់ ថាជាឯកសារភស្តុតាងដែលត្រូវដាក់ចូលក្នុងការពិភាក្សាដេញដោល។

---

[3] សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ **E208**។ សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកចម្លើយសាក្សីនានាដែលទាក់ទងនឹងដំណាក់កាលទី២ នៃការជម្លៀសប្រជាជន និងបញ្ហាភស្តុតាងផ្សេងទៀត ជាមួយឧបសម្ព័ន្ធសម្ងាត់ I, II, III និងឧបសម្ព័ន្ធ IV សាធារណៈ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ **E208/2**។

[4] សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ពី១-១៦ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ **E96/8**។

៧. ជាសរុបមក និងដោយមិនគិតដល់សក្ខីកម្មជាលាយលក្ខណ៍អក្សរដែលសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង[5] ចំនួនឯកសារដែលសហព្រះរាជអាជ្ញាមានបំណងចង់ឱ្យទទួលយកជាឯកសារភស្តុតាង មានរហូតដល់ទៅ ២៤១៦ ទៅហើយ។ តាមការយល់ឃើញរបស់លោក ខៀវ សំផន ការដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សាដេញដោល នូវឯកសារដែលមានចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នេះ ពុំបានអនុញ្ញាតឱ្យអង្គជំនុំជម្រះអាចមានសមត្ថភាពក្នុងការត្រួតពិនិត្យបានយ៉ាងហ្មត់ចត់ទៅលើសក្ខីកម្មជាលាយលក្ខណ៍អក្សរបានឡើយ ខណៈដែលអ្នកផ្ដល់សក្ខីកម្មទាំងនោះពុំត្រូវបានគេកោះហៅឱ្យចូលខ្លួនមកបំភ្លឺនៅក្នុងអង្គសវនាការទេនោះ។

៨. អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា សក្ខីកម្មដែលប្រមូលបាននៅក្នុងដំណាក់កាលស៊ើបសួរ ត្រូវបានទទួលស្គាល់ថាជាសក្ខីកម្មដែលមានភាពសមហេតុសមផល និង គួរឱ្យជឿទុកចិត្តបាន។ អង្គជំនុំជម្រះក៏បានចង្អុលបង្ហាញផងដែរថា អង្គជំនុំជម្រះនឹងធ្វើការត្រួតពិនិត្យមើលអំពីភាពពុំស៊ីសង្វាក់គ្នារវាងឯកសាថតសំឡេងនៃការផ្ដល់សក្ខីកម្ម និងរបាយការណ៍ស្ដាប់ចម្លើយសាក្សីដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត តែក្នុងករណីដែលភាពពុំស៊ីសង្វាក់គ្នានោះត្រូវបានគេកំណត់អត្តសញ្ញាណច្បាស់ និងតែក្នុងករណីនៃភាពពុំស៊ីសង្វាក់គ្នាទៅលើខ្លឹមសារ ដែលជាហេតុផលមួយសំខាន់សម្រាប់ការកាត់សេចក្ដី[6]។

---

[5] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងអនុស្សរណៈ **E208/3** និងសេចក្ដីសម្រេចលើសំណើសុំរបស់សហព្រះអាជ្ញាអនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងឯកសារនានា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង **E96/7** ដោយរួមបញ្ចូលទាំងឧបសម្ព័ន្ធសម្ងាត់ទី១ និងទី២ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ **E208/4**។

[6] សេចក្ដីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ **E96/7** ("សេចក្ដីសម្រេចចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២") កថាខណ្ឌ ២៦។

៩. ផ្ទុយទៅវិញ ពាក់ព័ន្ធទៅនឹងភាពពុំច្បាស់លាស់នានាក្នុងចំណោមភាពពុំច្បាស់លាស់ដទៃទៀត[7] នៃលក្ខខណ្ឌទាំងឡាយដែលអនុវត្តចំពោះការស្តាប់យកចម្លើយពីលោក ភី ភួន លោក ខៀវ សំផន អាចបង្ហាញដោយស្របច្បាប់នូវភាពមន្ទិលមួយចំនួនរបស់ខ្លួន ចំពោះសុច្ចរិតភាពនៃនីតិវិធីដែលអនុវត្តដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ ហេតុដូចនេះហើយ អង្គជំនុំជម្រះត្រូវធ្វើការត្រួតពិនិត្យយ៉ាងផ្ចិតផ្ចង់ ទៅលើភាពដែលអាចជឿទុកចិត្តបាននៃខ្លឹមសាររបស់សក្ខីកម្មជាលាយលក្ខណ៍អក្សរនោះ។ ដូច្នេះ មេធាវីការពារក្តីនឹងត្រូវចំណាយពេលវេលាដ៏ច្រើន ដើម្បីពិនិត្យមើលម្តង**មួយៗ**នូវឯកសារជាលាយលក្ខណ៍អក្សរ និង ឯកសារថតសំឡេងទាំង ២៤១៦ នោះ។ ការដាក់បញ្ចូលឯកសារទាំងអស់នោះទៅក្នុងកិច្ចពិភាក្សាដេញដោល នឹងតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងចំណាយពេលវេលាដ៏មានតម្លៃដើម្បីរៀបចំកម្មវិធីសវនាការដែលអនុញ្ញាតឱ្យភាគីអាចលើកពីសេចក្តីជំទាស់របស់ខ្លួននោះ។

១០. នៅក្នុងចក្ខុវិស័យបែបនេះ សំណើសុំរបស់សហព្រះរាជអាជ្ញាមានលក្ខណៈជ្រុលហួសហេតុ និង ផ្ទុយទៅនឹងកិច្ចខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃនីតិវិធី ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុរបស់តុលាការ និងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះទោសយ៉ាងឆាប់រហ័ស។

១១. ជាពិសេស សំណើសុំបន្ថែមរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ បានបង្កើនចំនួនប្រភេទ និងវិសាលភាព នៃសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដែលខ្លួនមានបំណងដាក់ចូលក្នុងកិច្ចពិភាក្សា

---

[7] ដូចដែលមេធាវីការពារក្តីរបស់លោក អៀង សារី បានលើកឡើងនៅក្នុងសំណើរបស់ខ្លួនចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ ការអនុវត្តរបស់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការស្តាប់ចម្លើយសាក្សី មុននឹងថតសម្លេងការស្តាប់ចម្លើយនេះ មិនមែនពាក់ព័ន្ធតែករណីរបស់លោក ភី ភួន ប៉ុណ្ណោះនោះទេ, ឯកសារ **E221** កថាខណ្ឌ ១៨។ សូមមើលចម្លើយរបស់លោក អឿន តាន ដែលបានផ្តល់ក្នុងសវនាការ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ (ឯកសារ **E1/87.1** ទំព័រ ៣៤-៣៥)។

ដេញដោលលើសំណុំរឿង ០០២/០១។ សំណើសុំនេះភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធចំនួន ១៦ ដែលក្នុងនោះ ឧបសម្ព័ន្ធមួយចំនួនពាក់ព័ន្ធទៅនឹងប្រធានបទដែលស្ថិតនៅក្រៅ វិសាលភាពនៃរឿងក្ដី[8] ទាំងស្រុង។

១២. ផ្ទុយទៅវិញ សក្ខីកម្មនានាដែលសហព្រះរាជអាជ្ញាមានបំណងដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សាដេញដោល គឺជាសក្ខីកម្មរបស់សាក្សីដែលមានចំនួនដ៏ច្រើន នៅក្នុងឧបសម្ព័ន្ធដែលពាក់ព័ន្ធទៅនឹងប្រធានបទដែលពុំមានភាពសមហេតុផលសម្រាប់រឿងក្ដី ០០២/០១ ទៅវិញ ។ ឧបសម្ព័ន្ធ ៣ ដល់ ៩[9] ដែលពាក់ព័ន្ធទៅនឹងប្រធានបទនៃរឿងក្ដីបច្ចុប្បន្ន មានតែ ៤០៦ ឯកសារសក្ខីកម្មប៉ុណ្ណោះ។ ចំណែកឯឧបសម្ព័ន្ធ ១០ ដល់ ១៦ បែរជាមានឯកសារសក្ខីកម្មដល់ទៅ ១៣៨៧ ឯកសារ ទៅវិញ។

១៣. សហព្រះរាជអាជ្ញាយល់ឃើញថា ភាគីប្រហែលជាមិនត្រូវការពេលវេលាច្រើនសម្រាប់ធ្វើសេចក្ដីជំទាស់ទៅនឹងឯកសារនានា ដែលបានលើកឡើងដោយសំណើសុំដាក់បញ្ចូលទៅក្នុងការពិភាក្សាដេញដោលនោះ

---

[8] សំណើបន្ថែម (ឯកសារ **E96/8**) ជាពិសេស ឧបសម្ព័ន្ធទី១០ (*Cooperatives and worksites policy &widespread or systematic attack against the civilian population corroborative evidence*) ឧបសម្ព័ន្ធទី១១ (*Security centres and execution sites policy & widespread or systematic attack against the civilian population corroborative evidence*) ឧបសម្ព័ន្ធទី១២ (*JCE-Treatment of targeted groups policy and widespread or systematic attack against the civilian population corroborative evidence*) ឧបសម្ព័ន្ធទី១៣ (*Treatment of Buddhist policy & widespread or systematic attack against the civilian population corroborative evidence*) ឧបសម្ព័ន្ធទី១៤ (*Treatment of Cham policy & widespread or systematic attack against the civilian population corroborative evidence*) ឧបសម្ព័ន្ធទី១៥ (*Treatment of Vietnamese policy & widespread or systematic attack against the civilian population corroborative evidence*) ឧសម្ព័ន្ធទី១៦ (*Regulation of marriage policy & widespread and systematic attack against the civilian population corroborative evidence*)។

[9] ឧបសម្ព័ន្ធទី៣ ដល់ទី៩ នៃសំណើបន្ថែម (ឯកសារ **E96/8**) ពាក់ព័ន្ធនឹងប្រធានបទខាងក្រោម៖ ឧបសម្ព័ន្ធទី៣ (*Historical background corroborative evidence*) ឧបសម្ព័ន្ធទី៤ (*Administrative structures (centre) corroborative evidence*), ឧបសម្ព័ន្ធទី៥ (*Administrative structures (national) corroborative evidence*), ឧបសម្ព័ន្ធទី៦ (*Communications structure corroborative evidence*) ឧបសម្ព័ន្ធទី៧ (*Military structure corroborative evidence*) ឧបសម្ព័ន្ធទី៨ (*Armed conflict corroborative evidence*) ឧបសម្ព័ន្ធទី៩ (*Movement of the population policy & widespread or systematic attack against the civilian population corroborative evidence*)។

ទេ។ បើតាមការយល់ឃើញរបស់សហព្រះរាជអាជ្ញា "បទពិសោធន៍កន្លងមកបានបង្ហាញឲ្យឃើញថា នៅរាល់ពេលមានកិច្ចពិភាក្សាដេញដោលទៅលើឯកសារ ភាគីតែងតែលើកសេចក្តីជំទាស់ជាទូទៅទៅលើ ឯកសារទាំងមូល ពោលគឺពុំបានលើកសេចក្តីជំទាស់ទៅនឹងឯកសារណាមួយជាក់លាក់នោះទេ ហើយ ពាក់ព័ន្ធជាញឹកញាប់ទៅនឹងការបន្ថែមទម្ងន់លើឯកសារ ជៀសជាងទៅលើភាពដែលអាចទទួលបាននៃ ឯកសារទាំងនោះ"[10]។

១៤. ជាក់ស្តែង ដោយយោងទៅលើទំហំនៃឯកសារ និង កាលកំណត់ មេធាវីការពារក្តីមិនចង់បង្ខំចិត្តធ្វើតែ សេចក្តីជំទាស់ជាទូទៅនោះឡើយ។ ចំណុចនេះ មានលក្ខណៈផ្ទុយគ្នាទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំ ជម្រះដែលបានបញ្ជាក់យ៉ាងច្បាស់ដល់ភាគីថា អង្គជំនុំជម្រះមានបំណងស្តាប់តែសេចក្តីជំទាស់ណាដែល ធ្វើឡើងដោយជាក់ច្បាស់ សមហេតុផល និងចំគោលដៅ[11]។

១៥. នៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី ២០ ខែ មិថុនា អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងអំពីលក្ខណៈ វិនិច្ឆ័យ សម្រាប់ឲ្យការដាក់បញ្ចូលចម្លើយជាលាយលក្ខណ៍អក្សរ ឬ ឯកសារប្រតិចារឹកនៃការស្តាប់ ចម្លើយសាក្សីទៅក្នុងកិច្ចពិភាក្សាដេញដោល ត្រូវបានធ្វើឡើងដោយសមស្របនោះ[12]។ លោក ខៀវ សំផន យល់ឃើញថា សហព្រះរាជអាជ្ញាពុំបានគោរពតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលា ដំបូងនេះទេ។

១៦. សក្ខីកម្មជាលាយលក្ខណ៍អក្សររបស់សាក្សីដែលមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ ១០ ដល់ ១៦ នៃសំណើសុំ បន្ថែម ពាក់ព័ន្ធទៅនឹងប្រធានបទដែលពុំមានចំណងទាក់ទងជាមួយនឹងអង្គហេតុដែលជាកម្មវត្ថុនៃការជំនុំ ជម្រះលើកទីមួយនេះទេ។ ជាក់ស្តែង ឯកសារចម្លើយសាក្សី និង ឯកសារដទៃទៀត ដូចបានលើកឡើង

[10] សំណើបន្ថែម (ឯកសារ **E96/8**) កថាខណ្ឌ ៣៦។

[11] សេចក្តីសម្រេចចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៦ ដល់ ២៨។

[12] *យោងដូចខាងលើ* កថាខណ្ឌ ២៤។

ពុំមានភាពសមហេតុផល ហើយត្រូវតែគោរពទៅតាមលក្ខណៈវិនិច្ឆ័យតែមួយគត់ ដូចមានចែងនៅក្នុង វិធាន ៨៧ ៣) ក.[13] ។

១៧. ដោយឡែក ទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ក្នុងករណីមួយចំនួន ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង ឯកសារផ្តល់សក្ខីកម្មនានាដែលទទួលបានពីសំណាក់ស្ថាប័នក្រៅ អ.វ.ត.ក. អាចត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សាដេញដោលក៏ដោយ ក៏អង្គជំនុំជម្រះបានធ្វើការ រំលឹកផងដែរថា ឯកសារអស់ទាំងនោះពុំមែនត្រូវបានគេសន្មត់ថា មានភាពសមហេតុផល និងគួរឱ្យជឿទុកចិត្តបានដែរ[14]។

១៨. ដោយមើលឃើញអំពីភាពពុំច្បាស់លាស់ ពាក់ព័ន្ធនឹងភាពគួរឱ្យជឿជាក់បាននៃខ្លឹមសារចម្លើយសាក្សីដែលទទួលបានពីសំណាក់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងរយៈពេលដែលផ្តល់ឱ្យភាគី សម្រាប់ធ្វើសេចក្តីជំទាស់ទៅលើការដាក់បញ្ចូលឯកសារចម្លើយសាក្សីទាំងនោះ ទៅក្នុងកិច្ចពិភាក្សាដេញដោល លោក ខៀវ សំផន យល់ឃើញថា វាជាកាលៈទេសៈមួយមិនសូវសមស្របទេ ដែលសហព្រះរាជអាជ្ញាបានដាក់នូវឯកសារសក្ខីកម្មរបស់សាក្សីរាប់រយឯកសារ ដែលទទួលបានពីសំណាក់ការិយាល័យរបស់ខ្លួនផ្ទាល់[15] ពីអង្គភាពគាំពារជនរងគ្រោះ ឬ ពីសំណាក់ស្ថាប័នឯករាជ្យនានានោះ[16]។ ជាងនេះទៅទៀត

---

[13] *យោងដូចខាងលើ* កថាខណ្ឌ ២៩៖ អង្គជំនុំជម្រះគូសបញ្ជាក់ថា បណ្តឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត "ដែលមិនពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃសវនាការនៅក្នុងសំណុំរឿង ០០២/០១ អាចខកខានថែមទៀតក្នុងការបំពេញលក្ខណវិនិច្ឆ័យនៃភាពពាក់ព័ន្ធ អនុលោមតាមវិធាន ៨៧(៣)(ក) នៃវិធានផ្ទៃក្នុង"។

[14] *យោងដូចខាងលើ* កថាខណ្ឌ ២៩។

[15] សំណើបន្ថែម (ឯកសារ **E96/8**) កថាខណ្ឌ ២៦។ សហព្រះរាជអាជ្ញាធ្វើការចង្អុលបង្ហាញ ពាក់ព័ន្ធនឹងប្រការនេះ ថា "កំណត់ហេតុខ្លះត្រូវបានធ្វើកំណត់ត្រា ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហព្រះរាជអាជ្ញា ហើយទោះបីជាអ្នកស៊ើបអង្កេតនៃការិយាល័យសហព្រះរាជអាជ្ញា មិនទាមទារឱ្យមានភាពអព្យាក្រឹតដូចគ្នានឹងសហចៅក្រមស៊ើបអង្កេត នៅក្នុងកិច្ចស៊ើបសួររបស់ពួកគេក៏ដោយ ក៏កំណត់ហេតុទាំងនេះត្រូវតែអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះ យោងតាមសំណើនេះដែរ"។

ឯកសារសក្ខីកម្មទាំងនោះពុំជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងប្រធានបទដែលជាកម្មវត្ថុ នៃការជំនុំជម្រះលើសំណុំរឿង ០០២/០១ ឡើយ។

១៩. ក្រៅពីនេះ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងដោយត្រឹមត្រូវនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ " បើទៅបីជាសម្ភារៈនេះភាគច្រើនទំនងជានឹងត្រូវទទួលបានទម្ងន់ជាភ័ស្តុតាងតិចតួចប៉ុណ្ណោះក៏ដោយ ក៏ផលប៉ះពាល់នៃការគ្រប់គ្រងសវនាការនៃសំណើទាំងអស់នេះ (ដោយគិតអំពីសេចក្តីត្រូវការបកប្រែឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ ក៏ដូចជាសក្តានុពលដើម្បីផ្តល់ពេលវេលាច្រើន សម្រាប់ស្តាប់សវនាការសួរដេញដោលអំពីការជំទាស់ទៅនឹងសម្ភារៈនេះ) ហើយនៅតែសំខាន់ជាពិសេស ប្រសិនបើភាគីនានានូវតែរក្សាសំណើយ៉ាងទូលំទូលាយ សុំដាក់កំណត់ហេតុលាយលក្ខណ៍អក្សរ និងភស្តុតាងផ្សេងទៀតដ៏ច្រើនសន្ធឹកសន្ធាប់ នៅចំពោះមុខអង្គជំនុំជម្រះ[17]"។

២០. ទឡ្ហីករណ៍ដែលលើកឡើងដោយសហព្រះរាជអាជ្ញាហាក់ដូចជាពុំមានមូលហេតុសមស្របឡើយ។ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះពុំមានសាហ៊ុយ និង ពេលវេលាសម្រាប់ធ្វើការបកប្រែឯកសារសក្ខីកម្មទាំងនេះឡើយ[18]។ ជាក់ស្តែង ស្ទើរតែពុំមានបណ្តឹងណាមួយក្នុងចំណោមបណ្តឹងទាំង ៤២០ ដែលសហព្រះរាជអាជ្ញាមានបំណងដាក់ចូលក្នុងកិច្ចពិភាក្សាដេញដោល ត្រូវបានបកប្រែជាភាសាបារាំងនោះទេ រួមបញ្ចូលទាំងឯកសារសក្ខីកម្មមិនតិចជាង១០០ឯកសារទៀត ដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ឬពីសាលាសម្រាប់ការសិក្សាបូព៌ា និងអាហ្វ្រិក (School of Oriental and African Studies)។ ដោយឡែក "ឯកសារបកប្រែ" ទៅជាភាសាអង់គ្លេសមួយចំនួនធំ គឺសុទ្ធសឹងជា **ឯកសារ**

---

[16] សហព្រះរាជអាជ្ញាមានបំណងចង់ឲ្យដាក់បញ្ចូលនៅចំពោះមុខអង្គជំនុំជម្រះ នូវកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ៤០៩ នាក់ (ស្មើនឹង ១២២២ ឯកសារ) ព្រមទាំងចម្លើយចំនួន ៣២០ (ស្មើនឹង ៤២០ ឯកសារ) ដែលមជ្ឈមណ្ឌលកម្ពុជា (DC-Cam) និងសាលាសម្រាប់ការសិក្សាបូព៌ា និងអាហ្វ្រិក *(School of Oriental and African Studie)* ទទួលបាន។

[17] សេចក្តីសម្រេចចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ៣៤។

[18] សំណើបន្ថែម (ឯកសារ **E96/8**) កថាខណ្ឌ ៣៥។

**សង្ខេប** ដែលភាពគួរឲ្យជឿជាក់បាននៃឯកសារទាំងនេះ បានចោទជាបញ្ហាច្រើនជាងឯកសារសំណៅដើម[19]ទៅទៀត។

២១. ជាទីបញ្ចប់ ពាក់ព័ន្ធនឹងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរដែលអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតទទួលបាន ដូចមានបញ្ជាក់នៅក្នុងសំណើសុំចុះថ្ងៃទី ១៥ ខែ មិថុនា ថ្ងៃទី ៥ ខែ កក្កដា និងថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន បានបង្ហាញរួចមកហើយថា មានឯកសារកំណត់ហេតុស្តាប់ចម្លើយចំនួន ៧៩ ដែលពុំមានសំណៅថតសម្លេង។ ជាក់ស្តែង អង្គជំនុំជម្រះបានបញ្ជាក់រួចមកហើយថា អង្គជំនុំជម្រះអាចជំទាស់អំពីភាពដែលអាចគួរឲ្យជឿជាក់បាននៃកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរទាំងនោះ តែក្នុងករណីដែលមានភាពផ្ទុយគ្នាត្រូវបានគេរកឃើញយ៉ាងជាក់ច្បាស់ និង គួរឲ្យជឿបាន រវាងកំណត់ហេតុស្តាប់ចម្លើយសាក្សី និង ឯកសារថតសម្លេងនោះ[20]។ ដូច្នេះ ការដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សាដេញដោលនូវឯកសារសក្ខីកម្មរបស់សាក្សីជាលាយលក្ខណ៍អក្សរ ដោយពុំមានឯកសារថតសម្លេង បានធ្វើឲ្យមេធាវីការពារក្តីបាត់បង់នូវមធ្យោបាយក្នុងការធ្វើសេចក្តីជំទាស់របស់ខ្លួនទៅនឹងការដាក់នេះ។

២២. ផ្អែកទៅលើហេតុផលទាំងអស់នេះ មេធាវីការពារក្តីយល់ឃើញថា សហព្រះរាជអាជ្ញាពុំបានគោរពតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានគោលដៅធានាប្រសិទ្ធភាពនៃនីតិវិធី និង ការគោរពដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់សេចក្តីយ៉ាងឆាប់រហ័ស និង ប្រកបដោយយុត្តិធម៌។ ការដែលសហព្រះរាជអាជ្ញាមានការខ្ជីខ្ជា ដោយមិនបានសម្រិតសម្រាំងយកតែសក្ខីកម្មដែលមានលក្ខណៈសមហេតុផល ពីក្នុងបញ្ជីរបស់ខ្លួន មកដាក់បញ្ចូលក្នុងកិច្ចពិភាក្សាដេញដោលសហព្រះរាជអាជ្ញាបានអាក់ខានក្នុងការបំពេញកាតព្វកិច្ចរក្សាភាពហ្មត់ចត់របស់ខ្លួន។ ប្រសិនណាជាកំហុសនេះ មិន

[19] *យោងដូចខាងលើ* កថាខណ្ឌ ២៥ និង ៣៥។

[20] សេចក្តីសម្រេចចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ២៧។

ត្រូវបានកែតម្រូវទេនោះ វានឹងបណ្ដាលឲ្យមានការអូសបន្លាយនីតិវិធីឥតប្រយោជន៍ និង ពុំសមហេតុផល ព្រមទាំងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់លោក ខៀវ សំផន ទៀតផង។

២៣. **ហេតុដូច្នេះ** លោក ខៀវ សំផន សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង មេត្តា៖

-**សម្រេចតាម** សំណើសុំរបស់លោក អៀង សារី ដោយបង្គាប់ឲ្យមានការកោះហៅអ្នកបកប្រែដែលបានចូលរួមក្នុងការស្ដាប់យកចម្លើយលើកទី ២ លើសាក្សីឈ្មោះ ភី ភួន ឲ្យចូលមកបំភ្លឺក្នុងសវនាការ និង

- **បង្គាប់** ឲ្យសហព្រះរាជអាជ្ញាធ្វើការកែសម្រួលសំណើសុំរបស់ខ្លួនចុះថ្ងៃទី ១៥ ខែ មិថុនា ថ្ងៃទី ៥ ខែ កក្កដា និងថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ ដោយផ្អែកទៅលើសេចក្ដីណែនាំរបស់អង្គជំនុំជម្រះ ដែលមានគោលដៅពង្រឹងនូវប្រសិទ្ធភាពនៃនីតិវិធី និងអនុញ្ញាតឲ្យមេធាវីការពារក្ដីអាចធ្វើការលើកឡើងនូវសេចក្ដីជំទាស់ស្របតាមសេចក្ដីណែនាំនេះ។

| | | | |
|---|---|---|---|
| | មេធាវី **គង់ សំអុន**<br><br>មេធាវី **Anta GUISSÉ**<br><br>មេធាវី **Arthur VERCKEN**<br><br>មេធាវី **Jacques VERGÈS** | ភ្នំពេញ<br><br>ភ្នំពេញ<br><br>ប៉ារីស<br><br>ប៉ារីស | |
| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |